ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តពោធិ៍សាត់

សាលក្រមព្រហ្មទណ្ឌ

-លេខ: ០១ "ខ"

-ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៣

-សំណុំរឿងព្រហ្មទណ្ឌលេខ: ៤៦

ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២២

-សំណុំរឿងស៊ើបសួរលេខ: ៤៨

ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២

-សំណុំរឿងជំនុំជម្រះលេខ: ៣៣០

ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២២

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តពោធិ៍សាត់

បានបើកសវនាការជាសាធារណៈនៅថ្ងៃទីប្រាំបី ខែធ្នូ ឆ្នាំពីរពាន់ម្ភៃពីរ
វេលាម៉ោងប្រាំបី និងសូន្យៗនាទីព្រឹក ដោយមានសមាសភាព៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងខេត្តពោធិ៍សាត់ ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងខេត្តពោធិ៍សាត់ ជាចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមសាលាដំបូងខេត្តពោធិ៍សាត់ ជាចៅក្រមប្រឹក្សា

### តំណាងអយ្យការ

ឯកឧត្តម [redacted] ព្រះរាជអាជ្ញារងសាលាដំបូងខេត្តពោធិ៍សាត់

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តពោធិ៍សាត់

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៤៦ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២២ដែលមានជនជាប់ចោទ៖

១-ឈ្មោះ[redacted] **ផា ហៅ ផា** ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅ [redacted] ខេត្តពោធិ៍សាត់ ទីលំនៅមុនពេលឃាត់ខ្លួននៅ [redacted] ខេត្តពោធិ៍សាត់ ប្រពន្ធឈ្មោះ [redacted] ផា (លែងលះ) មានកូន០៣នាក់ ឪពុកឈ្មោះ [redacted] រី (ស្លាប់) ម្តាយឈ្មោះ[redacted] សារឿន (រស់) ជានីតិជន កម្រិតវប្បធម៌ថ្នាក់ទី៨ ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន ។

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦៨ ឃខ/២២ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តពោធិ៍សាត់ ។

<u>ជាប់ចោទពីបទ:</u> **រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិខ្វារ ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៦ និង មាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ **រី ផា** ។

២-ឈ្មោ[redacted] **ប៊ុនណារ័ត្ន ហៅ សារ៉ាយ** ភេទប្រុស កើតឆ្នាំ១៩៨៤ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិ[redacted] ខេត្តបាត់ដំបង ទីលំនៅបច្ចុប្បន្ននៅ[redacted] ខេត្តពោធិ៍សាត់ ប្រពន្ធឈ្មោះ [redacted] គន្ធា ឪពុកឈ្មោះ [redacted] ប៊ុនណារិទ្ធ (រស់) ម្តាយឈ្មោះ[redacted] សុខា (រស់) ជានីតិជន កម្រិតវប្បធម៌ថ្នាក់ទី៥ថ្មី ប្រវត្តិនៃការផ្តន្ទាទោសពីមុន គ្មាន ។(គេចខ្លួន)

<u>ជាប់ចោទពីបទ:</u> **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិសិរីគន្ធា ឃុំតាលោ ស្រុកតាលោសែនជ័យ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned with CamScanner

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]ប៊ុនណារ័ត្ន ។

## អង្គហេតុមានដូចតទៅ

កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង១៥ និង២១នាទី កម្លាំងជំនាញផ្នែកប្រឆាំងគ្រឿងញៀន ស្រុកបាកាន សហការជាមួយកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលរំលេច បានធ្វើការចុះបង្ក្រាបករណីរក្សាទុក ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ស្ថិតនៅភូមិខ្វាវ ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ ឃាត់ខ្លួនបានជនជាប់ចោទឈ្មោះ [redacted] ផា ហៅ ថា ភេទប្រុស អាយុ៤០ឆ្នាំ រស់នៅភូមិឃុំខាងលើ ។ តាមចម្លើយរបស់ឈ្មោះ [redacted] ផា ហៅ ថា បានឆ្លើយបំភ្លឺថា ខ្លួនចេះប្រើប្រាស់គ្រឿងញៀនរយៈពេល០២ឆ្នាំមកហើយ ។ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ វេលាម៉ោងប្រហែល៥ល្ងាច មានឈ្មោះ សារ៉ាយ ភេទប្រុស អាយុប្រហែល៣០ឆ្នាំ ប្រើប្រាស់ទូរស័ព្ទលេខ០៩៦ ៩៦ ៨៤ ៩២០ រស់នៅភូមិសិរីគន្ធា ឃុំតាលោ ស្រុកតាលោសែនជ័យ ខេត្តពោធិ៍សាត់ សួរមកខ្លួនថាអស់អីវ៉ាន់នៅ? ខ្លួនថាអស់ហើយ គាត់សួរខ្លួនថាយកប៉ុន្មានទៀត ខ្លួនឆ្លើយថាយកដូចរាល់ដងចំនួន ២,៤០០,០០០រៀល ឈ្មោះ សារ៉ាយ បានឱ្យខ្លួនទៅយកថ្នាំញៀនពីគេដែលនៅខាងកើតស្ពានប្រឡាយ១៧មេសា ប្រហែល៣០០ម៉ែត្រ ពេលខ្លួនទៅដល់មិនបានជួបគេទេ គឺឈ្មោះ សារ៉ាយ ខ្ចប់ថ្នាំញៀនដាក់ក្នុងថង់ពណ៌ខ្មៅ ទុកនៅលើស្មៅខ្លួនក៏រើសយកមកផ្ទះដើម្បីលក់បន្ត ។ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោងប្រហែល៣រសៀល ខ្លួនកំពុងតែប្រើប្រាស់ថ្នាំញៀន និង លក់ថ្នាំញៀនឱ្យគេនៅផ្ទះរបស់ខ្លួនស្រាប់តែប៉ូលីសមកដល់ផ្ទះខ្លួន និងឆែកឆេរលើខ្លួនឃើញថ្នាំញៀនចំនួន០១កញ្ចប់ធំ និងឆែកឆេររកឃើញថ្នាំញៀន១កញ្ចប់ទៀតជារបស់ខ្លួន ។ កន្លងមកខ្លួនទិញពីឈ្មោះ សារ៉ាយ បានប្រហែលចំនួន០៧ដង និងក្នុង០១ដង តម្លៃ ២,៤០០,០០០ រៀល ពេលបានថ្នាំញៀន ខ្លួនបានវេរលុយឱ្យទៅឈ្មោះ សារ៉ាយ ជាមុន ទើបគេប្រគល់ថ្នាំញៀនឱ្យខ្លួន ។ ករណីនេះត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួនរួមទាំងវត្ថុតាង បញ្ជូនមកអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ចាត់ការតាមនីតិវិធីច្បាប់ ។

-**បានឃើញ** របាយការណ៍លេខ: ០១៣ របក ចុះថ្ងៃទី០៤ ខែ កុម្ភៈ ឆ្នាំ ២០២២ របស់ការិយាល័យប្រឆាំងគ្រឿងញៀន ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ១៦៨ អក/២២ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ: ១៣៧២ អក/២២ ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ ។

-**បានឃើញ** ដីកាដំណោះស្រាយលេខ: ២២៩៦ ពសព្រទ/២២ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តពោធិ៍សាត់ ។

-**បានឃើញ** ដីកាសម្រេចដាក់រឿងជំនុំជម្រះលេខ ៥៣២ ពសជរ/២២ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះសាលាដំបូងខេត្តពោធិ៍សាត់ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ផា បានឆ្លើយនាពេលសវនាការថា កាលពីថ្ងៃ ០៣ ខែ កុម្ភៈ ឆ្នាំ២០២២ឈ្មោះ សារ៉ាយ ភេទប្រុស បានទូរស័ព្ទមកខ្លួនសួរថា ខ្លួនអស់ឥវ៉ាន់(គ្រឿងញៀន)ឬនៅ ខ្លួនក៏បានឆ្លើយប្រាប់គេវិញថា

អស់ហើយ ហើយគេសួរខ្លួនថាយកប៉ុន្មាន ។ ខ្លួនក៏បានប្រាប់ទៅវិញថា ទិញដូចរាល់ដងចំនួន២,៤០០,០០០ រៀល ។ ខ្លួនលក់គ្រឿងញៀនឱ្យអ្នកដទៃនេះចំនួន០៧ខែមកហើយ ដោយមួយកញ្ចប់ចំណេញពី៣ទៅ៤ម៉ឺនរៀល ហើយខ្លួនលក់គ្រឿងញៀននៅផ្ទះខ្លួនតែម្តង ។ ចំពោះឈ្មោះ សារ៉ាយ នេះគឺខ្លួនមិនស្គាល់ផ្ទះរបស់គេទេ ។ ពេលសមត្ថកិច្ចឃាត់ខ្លួនដកហូតបានគ្រឿងញៀនមួយកញ្ចប់ធំ ។ ក្រៅពីថ្នាំញៀនសមត្ថកិច្ចបានដកហូតទូរស័ព្ទមួយគ្រឿង ។ ខ្លួនមានកូន០៣នាក់ និងម្តាយចាស់ម្នាក់ក្នុងបន្ទុក ។ មុនពេលសមត្ថកិច្ចឃាត់ខ្លួនខ្លួនមានមុខរបរជាជាងជួសជុលផ្ទះឱ្យគេ ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

បន្ទាប់ពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទនាពេលសវនាការរួចមក តំណាងអយ្យការយល់ឃើញថានៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២២ ស្ថិតនៅភូមិខ្វារ ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ ពិតជាមានអំពើជួញដូរ រក្សា និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន មួយបានកើតឡើងប្រាកដមែន ។ យល់ឃើញថាជនជាប់ចោទឈ្មោះ [redacted] ផា បានឆ្លើយសារភាពនូវអំពើដែលខ្លួនប្រព្រឹត្តដោយទិញពីឈ្មោះ សារ៉ាយ ហើយជនជាប់ចោទឈ្មោះ រី ផា បានសហការជាមួយមន្ត្រីដើម្បីចាប់ខ្លួនឈ្មោះ [redacted] ប៊ុណ្ណាវ័ត្ត ផងដែរ ដោយការចង្អុលបង្ហាញនេះជាការសហការជាមួយសមត្ថកិច្ចក្នុងការចុះបង្ក្រាបនេះ ច្បាប់កំណត់ផ្តល់ស្ថានសម្រាលទោសដល់ជនជាប់ចោទផងដែរ ។ ម្យ៉ាងវិញទៀតជនជាប់ចោទមានកូន០៣នាក់ក្នុងបន្ទុក និងម្តាយចាស់ជរា ហើយជនជាប់ចោទបានភ្ញាក់រលឹកផងដែរ។ ហេតុដូច្នេះតំណាងអយ្យការប្តឹងសុំដល់ប្រធានក្រុមប្រឹក្សាជំនុំជម្រះឱ្យផ្តន្ទាទោសជនជាប់ចោទឈ្មោះ [redacted] ផា តាមមាត្រា ៤០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផ្តន្ទាទោសជនជាប់ចោទឈ្មោះ ជ័យ ប៊ុនណាវ័ត្ត តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងគប្បីចេញដីកាចាប់ខ្លួនជនជាប់ចោទរូបនេះតាមច្បាប់ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-មេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា: ក្រោយពីបានស្តាប់ការសាកសួរដេញដោលលើកូនក្តីខ្លួននាពេលសវនាការរួចមក ក្នុងនាមជាមេធាវីការពារសិទ្ធិឱ្យកូនក្តី ខ្លួនសូមទទួលយកការសន្និដ្ឋានរបស់តំណាងអយ្យការទាំងស្រុង ។ មួយវិញទៀតខ្លួនស្នើសុំក្រុមប្រឹក្សាជំនុំជម្រះបដិសេធចោលនូវដីកាដំណោះស្រាយលេខ ២២៨៦ ពសព្រ១/២២ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២២ ដែលធ្វើការចោទប្រកាន់កូនក្តីខ្លួន រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា ៤០ កថាខណ្ឌទី៦ មកជា មាត្រា ៤០ កថាខណ្ឌទី៥វិញ និងសំណូមពរដល់ក្រុមប្រឹក្សាជំនុំជម្រះមេត្តាពិចារណាជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង ដោយកូនក្តីខ្លួនសព្វថ្ងៃមានកូន១ក្នុងបន្ទុក និង មានម្តាយចាស់ជរាដោយមិនមាននរណាមើលខុសត្រូវឡើយ ។

-មេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានការពារថា: ដោយហេតុថាកូនក្តីខ្លួនពុំបានបង្ហាញខ្លួននាពេលសវនាការនេះ ហេតុដូចនេះស្នើសុំដល់ក្រុមប្រឹក្សាជំនុំជម្រះសម្រេចតាមច្បាប់ ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] ផា បាននិយាយសំដីចុងក្រោយបង្អស់របស់ : ខ្លួនសូមឱ្យតុលាការមេត្តាបន្ធូរបន្ថយទោសដល់ខ្លួនផង ។



Scanned with CamScanner

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់

## **សំអាងហេតុ**

១-កាលពីថ្ងៃទី០៣ ខែ កុម្ភៈ ឆ្នាំ ២០២២ ស្ថិតនៅភូមិខ្វាវ ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ ពិតជាអំពើ រក្សាទុក ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន មួយបានកើតឡើង ដែលត្រូវបានសមត្ថកិច្ចចុះទៅបង្ក្រាប និងធ្វើការឃាត់ខ្លួនបានជនសង្ស័យម្នាក់ឈ្មោះ[redacted]ផា ផងដែរ ។

២-តាមដីកាដំណោះស្រាយលេខ: ២២៨៦ ពសព្រទ/២២ ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តពោធិ៍សាត់ បានសម្រេចបញ្ជូន៖

ក-ជនជាប់ចោទឈ្មោះ[redacted]ផា ហៅ ផា ភេទប្រុស អាយុ៤០ឆ្នាំ មកជំនុំជម្រះពីបទ រក្សាទុក ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្វាវ ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌទី៦ និង មាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនណារ័ត្ន ហៅ សារ៉ាយ ភេទប្រុស អាយុ៣៨ឆ្នាំ មកជំនុំជម្រះពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិសិរីគន្ធា ឃុំតាលោ ស្រុកតាលោសែនជ័យ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ[redacted]ផា ហៅ ផា ដែលបានឆ្លើយសារភាពថា ខ្លួនពិតជាបានទិញគ្រឿងញៀនពីឈ្មោះ សារ៉ាយ ចំនួន២,៤០០,០០០រៀល ប្រាកដមែន ។ ខ្លួនលក់គ្រឿងញៀនឱ្យអ្នកដទៃបានរយៈពេល០៧ខែមកហើយ ដោយមួយកញ្ចប់ចំណេញពី៣ទៅ៤ម៉ឺនរៀល ហើយខ្លួនលក់គ្រឿងញៀននៅផ្ទះខ្លួនតែម្តង ។ ពេលសមត្ថកិច្ចឃាត់ខ្លួនដកហូតបានគ្រឿងញៀនមួយកញ្ចប់ធំ ។

តាមចម្លើយសារភាពរបស់ជនជាប់ចោទខាងលើ ឃើញថាមានភាពស៊ីសង្វាក់ទៅនឹងអង្គហេតុក៏ដូចជាវត្ថុតាងជាគ្រឿងញៀនដែលសមត្ថកិច្ចឆែកឆេររកឃើញនៅផ្ទះរបស់ជនជាប់ចោទផងដែរ ដែលសកម្មភាពក្នុងការរក្សាទុកគ្រឿងញៀន និងលក់គ្រឿងញៀនឱ្យអ្នកដទៃរបស់ជនជាប់ចោទនេះបង្ហាញឱ្យឃើញពីចេតនាទុច្ចរិតក្នុងការប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់របស់តំណាងអយ្យការប្រាកដមែន ។ ពាក់ព័ន្ធនឹងការចោទប្រកាន់ចំពោះការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ឃើញថាយោងតាមកំណត់ហេតុធ្វើតេស្តស្វែងរកសារធាតុញៀនលើជនជាប់ចោទឈ្មោះ[redacted] ផា ជាលទ្ធផលគឺវិជ្ជមាន (+) មានសារធាតុញៀនក្នុងទឹកនោម ដែលបង្ហាញឱ្យឃើញថាជនជាប់ចោទពិតជាបានប្រើប្រាស់គ្រឿងញៀនប្រាកដមែន ។



Scanned with CamScanner

ប៉ុន្តែចំពោះដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តពោធិ៍សាត់ ដែលបានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ផា ហៅ ផា ភេទប្រុស អាយុ៤០ឆ្នាំ មកជំនុំជម្រះពីបទ រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្វាវ ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៦ និង មាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឃើញថាយោងតាមកំណត់ហេតុឃាត់ខ្លួនពីបទល្មើសជាក់ស្តែង និងកំណត់ហេតុបិទកញ្ចប់វត្ថុតាង ឃើញថាម្សៅក្រាមពណ៌សថ្លាសង្ស័យជាសារធាតុញៀនចំនួន០២កញ្ចប់ដែលសមត្ថកិច្ចរកឃើញគឺមានទម្ងន់ ៥៨,៧១ ក្រាម ថ្លឹងទាំងសំបក ។ ដូចនេះដើម្បីផ្តន្ទាទោសជនជាប់ចោទឱ្យត្រូវបទល្មើស និងអំពើប្រព្រឹត្តរបស់ជនជាប់ចោទ គប្បីតុលាការធ្វើការកែប្រែបទចោទប្រកាន់ពីបទ រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្វាវ ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌទី៦ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកជា បទ រក្សាទុក ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្វាវ ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៥ ចំណុច១០ និង មាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន វិញ ។

ចំពោះជនជាប់ចោទឈ្មោះ [redacted] ប៊ុនណារ័ត្ន ហៅ សារ៉ាយ ឃើញថាក្រោយពីបានឆ្លើយបំភ្លឺរបស់ជនជាប់ចោទឈ្មោះ [redacted] ផា ដែលបានអះអាងថាទិញគ្រឿងញៀន ពីឈ្មោះ សារ៉ាយ ។ តាមការបំភ្លឺនេះចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឱ្យស្រាវជ្រាវអត្តសញ្ញាណរបស់ជនជាប់ចោទ និង ក្រោយមកបានទទួលសារតាជាតិរបស់ជនជាប់ចោទ ហើយតុលាការបានកោះហៅជនជាប់ចោទឈ្មោះ [redacted] ប៊ុនណារ័ត្ន ហៅ សារ៉ាយ ឱ្យចូលមកឆ្លើយបំភ្លឺជូនតុលាការតាមនីតិវិធីច្បាប់ ប៉ុន្តែជនជាប់ចោទពុំបានចូលខ្លួនមកឆ្លើយបំភ្លឺជូនតុលាការនោះទេ ហើយសមត្ថកិច្ចក៏បានបញ្ជាក់ផងដែរថាជនជាប់ចោទរូបនេះបានគេចខ្លួនមិនដែលនៅផ្ទះនោះទេ ។ សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនណារ័ត្ន ហៅ សារ៉ាយ បង្ហាញឱ្យឃើញពីចេតនាទុច្ចរិតក្នុងការគេចវេសពីការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើប្រព្រឹត្តរបស់ជនជាប់ចោទ។ ម៉្យាងវិញទៀតក្រោយពីបានពិនិត្យសំណុំរឿង និងឯកសារភស្តុតាងនានាក្នុងសំណុំរឿងឃើញថាតាមដីកាដំណោះស្រាយស្រាយលេខៈ ២២៨៦ ពសព្រទ/២២ ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តពោធិ៍សាត់ ដែលបានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ប៊ុនណារ័ត្ន ហៅ សារ៉ាយ ភេទប្រុស អាយុ៣៨ឆ្នាំ មកជំនុំជម្រះពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅ ភូមិសិរីគន្ធា ឃុំតាលោ ស្រុកតាលោសែនជ័យ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យ ផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនឃើញថាមិនទាន់មានលក្ខណៈត្រឹមត្រូវតាមអំពើល្មើសរបស់ជនជាប់ចោទឡើយ ។ ហេតុនេះគប្បីតុលាការធ្វើការកែប្រែបទចោទប្រកាន់ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្វាវ ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកជា បទ ជួញដូរដោយខុសច្បាប់នូវសារធាតុ



Scanned with CamScanner

ញៀន ប្រព្រឹត្តនៅភូមិខ្វាវ ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៥ ចំណុច១០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន វិញ និងគប្បីតុលាការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទរូបនេះមកផ្តន្ទាទោសតាមច្បាប់ ។

៤-តាមលទ្ធផលកោសលវិច័យគ្រឿងញៀនរបស់ជនជាប់ចោទឈ្មោះ [redacted] ផា លេខ ៣៥៨៦៩/២២ ម.ព.អ.ជ.ប.គ.៣ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២២ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបញ្ជាក់ថាសំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះមេតំហ្វេតាមីន ដែលមានកម្រិតភាពសុទ្ធ ៧២,៤៥% នៃទម្ងន់សរុបវាស្ថិតក្នុងតារាងទី២មាត្រា៥ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

៥-តាមកំណត់ហេតុស្តីពីការបើក ដកហូតសំណាក និង បិទកញ្ចប់វត្ថុតាង ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តពោធិ៍សាត់ឃើញថាគ្រឿងញៀនដែលដកហូតបានពីជនជាប់ចោទឈ្មោះ [redacted] ផា ជាប្រភេទម្សៅដែលមានទម្ងន់សរុប៥៥,២០(ហាសិបប្រាំក្បៀសម្ភៃ)ក្រាមជាសាច់ថ្នាំសុទ្ធ ។ ដូចនេះបរិមាណសុទ្ធមេតំហ្វេតាមីនមានចំនួន $\frac{៧២,៤៥x ៥៥,២០}{១០០}$ = ៣៩,៩៩ក្រាមដូចនេះតុលាការពិចារណាផ្តន្ទាទោសលើជនជាប់ចោទផ្អែកទៅលើសារធាតុញៀននេះ។

៦-អំពើប្រព្រឹត្តរបស់ជនជាប់ចោទធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ សន្តិសុខសង្គម និងប៉ះពាល់ដល់សុខភាពខ្លួន និងអ្នកដទៃទៀតផង ។

៧-ជនជាប់ចោទទាំងពីររូបជានីតិជនមានស្មារតីគ្រប់គ្រាន់ និងនីតិសម្បទាបរិបូរណ៍ហើយពុំមានសញ្ញាណណាមួយដែលនាំឱ្យមានមន្ទិលសង្ស័យថា ជននេះមានសតិវិបល្លាសស្មារតីក្នុងពេលប្រព្រឹត្តបទល្មើសនោះឡើយ ដូច្នេះជនជាប់ចោទជាសមត្ថជនអាចពិចារណា និងយល់ដឹងអំពីព្យសនកម្មដែលកើតចេញពីអំពើរបស់ខ្លួនហើយលក្ខខណ្ឌគតិយុត្តតម្រូវឱ្យទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្តនិងត្រូវបានច្បាប់កំណត់ថាជាបទល្មើសព្រហ្មទណ្ឌ ។

៨-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំឱ្យក្រុមប្រឹក្សាបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង ។ គប្បីតុលាការពិចារណា និងសម្រេច ។

៩-មានពិរុទ្ធគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើ៖

ក-ជនជាប់ចោទឈ្មោះ [redacted] ផា ហៅ ថា ភេទប្រុស អាយុ៤០ឆ្នាំ ពីបទ រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្វាវ ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌទី៥ ចំណុច១០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

ខ-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនណារ័ត្ន ហៅ សារ៉ាយ ភេទប្រុស អាយុ៣៨ឆ្នាំ ពីបទបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិខ្វាវ ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៥ ចំណុច១០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។



Scanned with CamScanner

១០-តាមកំណត់ហេតុប្រគល់ទទួលវត្ថុតាងចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២២ របស់លេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងខេត្តពោធិ៍សាត់រួមមាន៖

ក-ស្រោមសំបុត្រពណ៌គគីរបិទជិតចំនួន០១កញ្ចប់ ប៉ុន្តែដោយហេតុថានៅដំណាក់កាលចៅក្រមស៊ើបសួរបានបើកកញ្ចប់ ដើម្បីធ្វើកោសលវិច័យទៅលើម្សៅក្រាមដែលសង្ស័យថាជាគ្រឿងញៀនហើយនៅសល់ចំនួន៥៣,៦១ក្រាមរក្សាទុកនៅសាលាដំបូងខេត្តពោធិ៍សាត់ គប្បីតុលាការសម្រេចរឹបអូសបំផ្លាញចោល ។

ខ-ថង់ប្លាស្ទិកសម្រាប់ច្រករំលែកថ្នាំញៀនមួយចំនួនធំ ។

គ-ដែកកេះចំនួន០៦ ។

ឃ-ជញ្ជីងថ្លឹងចំនួន០១ ។

ង-កន្ត្រៃចំនួន០២ ។

ច-បំពង់ដែករំលែកថ្នាំញៀនចំនួន០១ ។

ដែលជាឧបករណ៍សម្រាប់ប្រព្រឹត្តបទល្មើស និង ជាវត្ថុគ្រោះថ្នាក់ គប្បីតុលាការសម្រេចរឹបអូសបំផ្លាញចោល។

ឆ-ទូរស័ព្ទដៃចំនួន០១គ្រឿង (ពណ៌ទឹកមាស ម៉ាក SAMSUNG បែកកញ្ចក់អេក្រង់) ដែលជាមធ្យោបាយសំរាប់ទំនាក់ទំនងក្នុងការប្រព្រឹត្តបទល្មើសគប្បីតុលាការសម្រេចរឹបអូសជាសម្បត្តិរដ្ឋ។

## ហេតុដូច្នេះវិនិច្ឆ័យសេចក្តី

១.កែប្រែចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted]ផា ហៅ ផា ភេទប្រុស អាយុ៤០ឆ្នាំ ពីបទ **រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិខ្វាវ ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៦ និង មាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកជា បទ **រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិខ្វាវ ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌទី៥ ចំណុច១០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន វិញ។

២.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **ផា ហៅ ផា** ភេទប្រុស អាយុ៤០ឆ្នាំ ដាក់ពន្ធនាគារកំណត់ **០៥ ឆ្នាំ (ប្រាំឆ្នាំ)** និង ពិន័យជាប្រាក់ចំនួន១០(ដប់) លានរៀល ដាក់ចូលថវិការដ្ឋ ។

ពីបទ **រក្សាទុក ជួញដូរ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិខ្វាវ ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌទី៥ ចំណុច១០ និងមាត្រា៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣.កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] **ប៊ុនណារ័ត្ន** ហៅ **សារ៉ាយ** ភេទប្រុស អាយុ៣៨ឆ្នាំ ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិខ្វាវ ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកជា បទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិខ្វាវ ឃុំរំលេច



Scanned with CamScanner

ស្រុកបាកាន ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៥ ចំណុច១០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន វិញ ។

៤.ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ប៊ុនណារ័ត្ន ហៅ សារ៉ាយ ភេទប្រុស អាយុ៣៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ **០៦ឆ្នាំ (ប្រាំមួយឆ្នាំ)** និង ពិន័យជាប្រាក់ចំនួន**១៥ (ដប់ប្រាំ) លានរៀល** ដាក់ចូលថវិការដ្ឋ ។

ពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិសិរីតន្ថា ឃុំតាលោ ស្រុកតាលោសែនជ័យ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌទី៥ ចំណុច១០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៥.បង្គាប់ឱ្យកងកម្លាំងសាធារណ:ឱ្យស្រាវជ្រាវរកចាប់ខ្លួន និងឃុំខ្លួនលើឈ្មោះ [redacted] ប៊ុណ្ណារ័ត្ន ហៅ សារ៉ាយ ភេទប្រុស អាយុ៣៨ឆ្នាំ ទៅពន្ធនាគារខេត្តពោធិ៍សាត់ដើម្បីអនុវត្តតាមអំណាចសាលក្រមនេះ ។

៦.វត្ថុចាប់យករួមមាន៖

ក-ម្សៅក្រាមដែលជាសារធាតុមេតំហ្វេតាមីនដែលសល់ពីការបើកសំណាកចំនួន៥៣,៦១ក្រាមរក្សាទុកនៅសាលាដំបូងខេត្តពោធិ៍សាត់ ត្រូវរឹបអូសបំផ្លាញចោល ។

ខ-ថង់ប្លាស្ទិកសម្រាប់ច្រករំលែកថ្នាំញៀនមួយចំនួនធំ ។

គ-ដែកកេះចំនួន០៦។

ឃ-ជញ្ជីងថ្លឹងចំនួន០១។

ង-កន្ត្រៃចំនួន០២។

ច-បំពង់ដែករំលែកថ្នាំញៀនចំនួន០១ ។

ត្រូវរឹបអូសបំផ្លាញចោល។

ឆ-ទូរស័ព្ទដៃចំនួន០១គ្រឿង (ពណ៌ទឹកមាស ម៉ាក SAMSUNG បែកកញ្ចក់អេក្រង់) ត្រូវរឹបអូសជាសម្បត្តិរដ្ឋ។

សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ផា ហៅ ផា និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ប៊ុនណារ័ត្ន ហៅ សារ៉ាយ និងប្រកាសជាសាធារណ:នៅថ្ងៃទី០៣ ខែមករា ឆ្នាំ ២០២៣។

ទុកសិទ្ធឱ្យប្តឹងទាស់ ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា [redacted]

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

បានចតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ១២កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

ធ្វើនៅពោធិ៍សាត់ ថ្ងៃទី០៣ ខែមករា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

Scanned with CamScanner